**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣២.សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សា រៀបចំ បង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



https://www.moj.gov.kh/kh/law-regular

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សា រៀបចំបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនគោក កម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម **ប្រាក់ សំអឿន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣.ឯកឧត្តម **សុខ សុភ័ក្ត្រ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤.ឯកឧត្តម **នួន ច័ន្ទរិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥.ឯកឧត្តម **សួស ប្រាថ្នា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៦.ឯកឧត្តម **ថូ សំណាង** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧.តំណាងក្រសួងទេសចរណ៍ | | សមាជិក |
| ៨.តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | | សមាជិក |
| ៩.តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន | | សមាជិក |
| ១០.អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | | សមាជិក |
| ១១.អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង | | សមាជិក |
| ១២.អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង | | សមាជិក |
| ១៣.អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |
| ១៤.អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | | សមាជិក |
| ១៥.អភិបាលនៃគណៈអភិបាលខេត្តតាកែវ | | សមាជិក |
| ១៦.អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | | សមាជិក |
| ១៧.អភិបាលនៃគណៈអភិបាលខេត្តរតនគិរី | | សមាជិក |
| ១៨.អភិបាលនៃគណៈអភិបាលខេត្តកំពត | | សមាជិក |
| ១៩.តំណាងអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | | សមាជិក |
| ២០.តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ | | សមាជិក |
| ២១.ឯកឧត្តម នាយឧត្តមសេនីយ៍ **ពិន ពិសិដ្ឋ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ | សមាជិក |
| ២២.លោក **សែ សុឃន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ២៣.លោក **ឆាន ច័យ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួងខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖



https://www.moj.gov.kh/kh/law-regular

- ដឹកនាំ សម្របសម្រួល សិក្សា និងរៀបចំផែនការមេស្តីពីការបង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម ដោយកំណត់លក្ខខណ្ឌវិនិច្ឆ័យនិងអាទិភាពជាក់លាក់ ថ្លឹងថ្លែងអំពីកត្តាសន្តិសុខ កិច្ចការពារអធិបតេយ្យភាពនិងបូរណភាពទឹកដី និងកិច្ចសម្រួលពាណិជ្ជកម្ម និងការចេញ-ចូលឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋឱ្យបានហ្មត់ចត់
- ពិគ្រោះ ពិភាក្សា និងសហការសម្របសម្រួលជាមួយក្រុមការងារបង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែនរបស់ភាគីវៀតណាម ដើម្បីរៀបចំផែនការមេរួមសម្រាប់បង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែនដែលមិនទាន់ស្មើកម្រិតគ្នា ច្រកទ្វារព្រំដែនដែលកម្ពុជានិងវៀតណាមបានឯកភាពគ្នាបង្កើតនិងដំឡើងកម្រិតរួចហើយ និងច្រកទ្វារព្រំដែនដែលរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមសុំបង្កើតនិងដំឡើងកម្រិត
- សិក្សានិងរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធី ដើម្បីជួយគាំទ្រដល់ការបង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម ឱ្យមានសង្គតិភាពជាមួយច្បាប់ លិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងជាធរមាន
- សិក្សានិងលើកគម្រោងកែលម្អនិងសាងសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធនានានៅតាមបណ្តាច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាមឱ្យបានសមស្រប
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលសម្រេចបាន វឌ្ឍនភាពការងារ និងបញ្ហាប្រឈម ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចតាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងាររបស់ខ្លួន ក្រុមការងារអន្តរក្រសួងត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រធានក្រុមការងារអន្តរក្រសួងមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមកិច្ចប្រជុំ ដើម្បីពិភាក្សាលើបញ្ហាប្រឈម ការស្វែងរកដំណោះស្រាយ និងអនុវត្តតាមស្មារតីសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួងទាំងអស់ ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងអនុវត្តការងាររបស់ខ្លួន។

ក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតឱ្យចូលរួមកិច្ចប្រជុំ ឬចូលរួមក្នុងកិច្ចការណាមួយតាមការចាំបាច់។

ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយបំពេញការងារតាមតម្រូវការចាំបាច់។

**ប្រការ ៥.-**

ការចំណាយផ្សេងៗនៅក្នុងការបំពេញការងាររបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័នសាមី។



https://www.moj.gov.kh/kh/law-regular

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តជាប់ព្រំដែនគោកជាមួយប្រទេសវៀតណាម និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular